# កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជន

ដើម្បីសមភាពយេនឌ័រ

# Youth Leadership Lab
## for Gender Equality




រៀបចំដោយបណ្ដាញមន្ត្រីវ័យក្មេង ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជន ដើម្បីសមភាពយេនឌ័រ

Youth Leadership Lab for Gender Equality

## ករណីសិក្សា

«លទ្ធផលសង្ខេប និងមេរៀនបទពិសោធន៍»

កម្មវិធីជុំវគ្គទី១

A Case Study – Youth Leadership Lab 1



# មាតិកា

1. អំពីកម្មវិធី
2. យុទ្ធសាស្ត្រ និងវឌ្ឍនភាពរបស់កម្មវិធី
3. មេរៀនពិសោធន៍
4. សន្និដ្ឋាន

Youth Leadership lab for Gender Equality

# អំពីកម្មវិធី

*កម្មវិធីអភិវឌ្ឍន៍ភាពដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ*
*Youth Leadership Lab for Gender Equality Program*

## គោលបំណង៖

**«អភិវឌ្ឍន៍យុវជននៅតាមគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសាធារណៈ ឱ្យក្លាយទៅជាអ្នកដឹកនាំ ដែលចូលរួមលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់នូវការរើសអើងលើស្រ្តី**នៅក្នុងគ្រួសារ សហគមន៍ និងសង្គម។»

កម្មវិធីជ្រើសរើស**យុវជន ២០រូប** និងធ្វើការអភិវឌ្ឍន៍សមត្ថភាពនិងភាពជាអ្នកដឹកនាំ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ តាមរយៈ៖



***វគ្គបណ្តុះបណ្តាលជាសេរី ការផ្លុះបញ្ចាំងនិងហ្វឹកហ្វឺន ចូលរួមព្រឹត្តិការណ៍ជាតិនិងវេទិកាសាធារណៈ ទស្សនកិច្ចសិក្សានិងដកស្រង់បទពិសោធន៍ ការរៀបចំសរសេរគម្រោង ការស្នើគម្រោងនិងការអនុវត្តគម្រោង ព្រមទាំងកម្មវិធីហាត់ការនៅតាមស្ថាប័នដៃគូ។***

*កម្មវិធីដែលផ្តួចផ្តើមឡើងដោយបណ្តាញមន្រ្តីវ័យក្មេង ក្រសួងកិច្ចការនារី*

# ការឆ្លើយតបនឹងក្របខណ្ឌជាតិនិងអន្តរជាតិ

- **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤** ចាត់ទុក «**ការអភិវឌ្ឍធនធានមនុស្ស**» ជាយុទ្ធសាស្ត្រអាទិភាពសំដៅ *លើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិកា និងស្មារតីទទួលខុសត្រូវ សុខភាពល្អនិងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។*
- **គោលដៅអភិវឌ្ឍប្រកបដោយចីរភាព** (២០១៦-២០៣០) គោលដៅទី៥ ក្នុងការធានាសមភាពយេនឌ័រ និងភាពអង់អាចដល់គ្រប់ស្ត្រីនិងក្មេងស្រី និង**គោលដៅទី៤** ក្នុងការអប់រំប្រកបដោយគុណភាព។
- **នារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣** នៅក្នុងយុទ្ធសាស្ត្រ ស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងវិស័យសាធារណៈ និងនយោបាយ ផ្តោតលើការអភិវឌ្ឍភាពជាអ្នកដឹកនាំនៅក្នុងចំណោមយុវជន ។









# វឌ្ឍនភាពរបស់កម្មវិធី

## វដ្តកាលទី១



**កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ វដ្តកាលទី១**

- ចាប់ផ្តើមដំណើរការនៅ<u>ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩</u>
- ក្រោមកិច្ចសហការភាពជាដៃគូ និងគាំទ្រដោយ៖

MINISTRY OF WOMEN'S AFFAIRS

UNDP

ស៊ុយអែត Sverige

OXFAM

RECOFTC

SILAKA

Cambodia Development Resource Institute

Coca-Cola

B-YooH

# យុទ្ធសាស្ត្ររបស់កម្មវិធី វដ្តកាលទី១

វគ្គជ្រើសរើស និងសិក្ខាសាលាតម្រង់ទិស

វគ្គបណ្ដុះបណ្ដាលជាសេរី និងឆ្លុះបញ្ចាំង ហ្វឹកហ្វឺន

ទស្សនកិច្ចសិក្សា និងចូលរួមវេទិកា

ការរៀបចំនិងអនុវត្តន៍គម្រោង

ការហាត់ការ



# ការជ្រើសរើសបេក្ខជន



https://fb.watch/4lvHt5KHiW/

- សេចក្តីប្រកាសនិងផ្សព្វផ្សាយ នៅតាមក្រសួងនិងស្ថាប័នដៃគូ និងបណ្តាញសង្គមរបស់ក្រសួង និងដៃគូ
- និស្សិត និងមន្ត្រីនៅតាមស្ថាប័ន ចំនួន ២៥ រូប បានដាក់ពាក្យចូលរួម ។
- កិច្ចសម្ភាសន៍ផ្ទាល់ជាមួយបេក្ខភាព ដើម្បីសិក្សាពីការយល់ឃើញរបស់បេក្ខភាពស្តីពីយេនឌ័រ និងការប្តេជ្ញាចិត្តចូលរួមក្នុងកម្មវិធី ។
- គណៈកម្មការកិច្ចសម្ភាសន៍៖ តំណាងក្រុមបណ្តាញមន្ត្រីវ័យក្មេង នៃក្រសួងកិច្ចការនារី និងតំណាងដៃគូ ដែលប្រព្រឹត្តចាប់ពីថ្ងៃទី១៦-១៩ ខែធ្នូ ឆ្នាំ២០១៩។
- បេក្ខភាពចំនួន២០រូប ត្រូវបានជ្រើសរើសចូលរួមក្នុងកម្មវិធី។

# សិក្ខាសាលាតម្រង់ទិស

## នៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៩

**តម្រង់ទិស ដើម្បីឱ្យបេក្ខភាពដែលបានជ្រើសរើស** បាន៖

- ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅពីកម្មវិធី រួមទាំង នីតិវិធី ដំណើរការ និងលក្ខខណ្ឌនានារបស់កម្មវិធី
- បង្កើតបរិយាកាសសម្រាប់ចង់បណ្ដាញទំនាក់ទំនង របស់សមាជិក ក្រុមការងារកម្មវិធី ដៃគូកម្មវិធី និងក្រុមគ្រូសម្របសម្រួលកម្មវិធី។









# វគ្គបណ្តុះបណ្តាល សេរីទី១ "គោលគំនិតនៃការបញ្ជ្រាបយេនឌ័រ"

## កាលពីថ្ងៃទី ២១-២៣ ខែមករា  ឆ្នាំ២០២០

**ប្រធានបទ៖** គោលគំនិតយេនឌ័រ ការវិភាគយេនឌ័រ សមធម៌ និង សមភាពយេនឌ័រ និងអន្តរទំនាក់ទំនង និងភាពប្រសព្វគ្នានៃអន្តរអត្តសញ្ញាណ។

**វិធីសាស្រ្ត៖** ផ្តល់មេរៀន, ធ្វើការឆ្លុះបញ្ចាំងខ្លួនឯង និងហ្វឹកហាត់ពីអ្នកសម្របសម្រួល និងកំណត់រកចំណុច ដែលត្រូវធ្វើបន្តក្រោយវគ្គ។

**លទ្ធផល៖** អ្នកចូលរួមបានសិក្សា និងស្វែងយល់ពីខ្លួនឯងកាន់តែស៊ីជម្រៅ តាមរយៈការឆ្លុះបញ្ចាំងបទពិសោធន៍ផ្ទាល់ខ្លួន និងការមានឥទ្ធិពលពីសង្គម ។

**អ្នកសម្របសម្រួល៖** គ្រូបណ្តុះបណ្តាល ក្រសួងកិច្ចការនារី និងអ្នកជំនាញពីស្ថាប័នដៃគូ។









# វគ្គបណ្ដុះបណ្ដាល សេរីទី២ “ភាពជាអ្នកដឹកនាំ និងការរៀបចំផែនការ”

ថ្ងៃទី ២៦-២៨ ខែកុម្ភៈ ឆ្នាំ២០២០

**ប្រធានបទ៖** ភាពជាអ្នកដឹកនាំ, ការស្វែងយល់ពីអំណាច, ការរៀបចំផែនការ ការបញ្ជ្រាបយេនឌ័រ, ជំនាញក្នុងការទំនាក់ទំនង និងគោលគំនិតនវានុវត្តន៍។

**វិធីសាស្រ្ត៖** ផ្ដល់មេរៀន, ធ្វើការឆ្លុះបញ្ចាំងខ្លួនឯង និងហ្វឹកហាត់ពីក្រុមអ្នកសម្របសម្រួល និងការកំណត់ចំណុចដែលខ្លួនត្រូវធ្វើបន្តក្រោយវគ្គ ។

**លទ្ធផល៖** យុវជនបានឆ្លុះបញ្ចាំងពីភាពជាអ្នកដឹកនាំរបស់ខ្លួន និងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដែលមានទស្សនៈយេនឌ័រ ដោយផ្ដោតលើការយល់ដឹងអំពីអំណាច ភាពជាអ្នកដឹកនាំ និងជំនាញក្នុងការទំនាក់ទំនង។

ផ្សារភ្ជាប់វគ្គទី១ និងទី២ អ្នកចូលរួមចាប់ផ្ដើមមានគំនិតសម្រាប់គម្រោង (Project idea) ក្នុងការដោះស្រាយបញ្ហាយេនឌ័រ និងការផ្ដើមចេញពីភាពជាអ្នកដឹកនាំរបស់ខ្លួន លើចំណុចដែលចង់ឃើញឱ្យមានភាពប្រសើរ។









# វគ្គបណ្តុះបណ្តាល សេរីទី៣

## "ភាពជា អ្នកដឹកនាំដើម្បីសមភាពយេនឌ័រ និងការអនុវត្តគម្រោង"

នៅថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ២០២០

<u>ប្រធានបទ៖</u> ការឆ្លុះបញ្ចាំងភាពជាអ្នកដឹកនាំដើម្បីសមភាពយេនឌ័រ ជំនាញសម្របសម្រួល សិល្បៈនៃការនិយាយជាសាធារណៈ ការអនុវត្តផែនការ ការតាមដាននិងវាយតម្លៃដែលមានទស្សនៈយេនឌ័រ ។

វគ្គបណ្តុះបណ្តាលនេះ បានពង្រឹងសមត្ថភាពរបស់សមាជិក ទាំងជំនាញទន់និងរឹង ដើម្បីក្លាយជាភ្នាក់ងារដោះស្រាយគម្លាតយេនឌ័រ និងលើកកម្ពស់ភាពជាអ្នកដឹកនាំបែបផ្លាស់ប្តូរជាវិជ្ជមាន រួមជាមួយនឹងទស្សនៈយេនឌ័រ ក្នុងការធ្វើសេចក្តីសម្រេច និងភាពជាអ្នកដឹកនាំរបស់ខ្លួន។

ជាមួយគ្នានេះ សមាជិក ២០នាក់ បានយល់កាន់តែច្បាស់អំពីយេនឌ័រ តួនាទីអំណាច និងភាពជឿជាក់ក្នុងការនិយាយ ក៏ដូចជាការអនុវត្តអាកប្បកិរិយាវិជ្ជមានជាដើម។









# ការផ្ដល់ឱកាសឱ្យចូលរួម ក្នុងព្រឹត្តការជាតិ និងវេទិកាសាធារណៈនានា






- នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៩ ក្រោមកិច្ចសហការរវាងវិស័យឯកជន (Be Your own Hero) និងបណ្ដាញមន្ត្រីវ័យក្មេងក្រសួងកិច្ចការនារី បានផ្ដល់ឱកាសដល់សមាជិកចូលរួមក្នុងវេទិកាដើម្បីលើកទឹកចិត្តពួកគេឱ្យឆ្ពោះទៅមុខចេញពី comfort zone របស់ពួកគេ បំពេញតាមក្ដីសុបិន និងបង្កើនភាពអង់អាចរបស់ពួកគេ។
- ថ្ងៃទី១-១០ ខែមីនា ឆ្នាំ២០២០ បានចូលរួម ក្នុងព្រឹត្តិការណ៍នានា នៃយុទ្ធនាការ អន្តរជាតិនារី ៨មីនា ឆ្នាំ២០២០ ។
- នៅថ្ងៃទី៨-១០ ខែតុលា ឆ្នាំ២០២០ បានចូលរួមក្នុងទិវាភាពជាអ្នកដឹកនាំប្រចាំឆ្នាំ២០២០ ដែលរៀបចំដោយក្រសួងកិច្ចការនារី និងវិស័យឯកជន ។

# ទស្សនៈកិច្ចសិក្សា
# និងដកស្រង់មេរៀនបទពិសោធន៍

<u>គោលបំណង និងការរំពឹងទុកៈ</u>

- ការស្វែងយល់អំពីស្ថានភាពជាក់ស្តែងនៅកន្លែងការងារ និងមូលដ្ឋាន
- ឆ្លុះបញ្ចាំងរវាងទ្រឹស្តីនិងមេរៀនដែលទទួលបានពីកម្មវិធី ជាមួយនឹងការអនុវត្តជាក់ស្តែង ព្រមទាំងស្វែងយល់ពីបញ្ហាប្រឈម និងមេរៀនបទពិសោធន៍នានា
- ស្វែងយល់អំពីតម្រូវការនិងបញ្ហាយេនឌ័រ នៅតាមក្រុមគោលដៅ និងដើម្បីធ្វើសុពលភាពគំនិតសម្រាប់រៀបចំគម្រោងស្នើរបស់ខ្លួន។

# ទស្សនៈកិច្ចសិក្សាស្វែងយល់ស្ថានភាពជាក់ស្តែង

## ការដឹកនាំ និងអភិវឌ្ឍសហគមន៍ព្រៃឈើ គាំទ្រដោយ RECOFTC

*នៅសហគមន៍ព្រៃក្បាលបី ខេត្តកំពង់ធំ*

ថ្ងៃទី១៩ - ២១ ខែតុលា ឆ្នាំ២០២០






យុវជនសមាជិកកម្មវិធី

បានសិក្សាស្វែងយល់ និងឆ្លុះបញ្ចាំងរវាងទ្រឹស្តីជាមួយនឹង ការអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍

ជាពិសេសអំពីស្ថានភាពយេនឌ័រ និងការអ្នកដឹកនាំ រួមទាំង បញ្ហាប្រឈម និងមេរៀនបទពិសោធន៍នានានៅសហគមន៍ព្រៃឈើ។





# ទស្សនៈកិច្ចសិក្សាស្វែងយល់ស្ថានភាពជាក់ស្តែង

## ការដឹកនាំនៅថ្នាក់ក្រោមជាតិ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី

*នៅខេត្តសៀមរាប*

នៅថ្ងៃទី៤-៦ ខែកុម្ភៈឆ្នាំ ២០២១





យុវជនកម្មវិធី

- បានបង្កើនការយល់ដឹងអំពីយេនឌ័រនិងភាពជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ
- យល់ដឹងពីស្ថានភាពជាក់ស្តែង តាមរយៈការចុះជួបស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងការដឹកនាំដែលឆ្លើយតប នឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ។





https://fb.watch/4lwmvQ4Z2n/

# ការរៀបចំគម្រោង, សេចក្តីស្នើ និងការអនុវត្តគម្រោង

Project formulation, project proposal and implementation.







- យុវជនកម្មវិធីម្នាក់ តម្រូវឱ្យមានគំនិតនៃដំណោះស្រាយលើបញ្ហាឬតម្រូវអាទិភាពណាមួយ (យេនឌ័រ យុវជន និងភាពជាអ្នកដឹកនាំ)
- កម្មវិធីបានហ្វឹកហ្វឺនអំពីរបៀបក្នុងការកំណត់គំនិតនៃគម្រោង (Project idea) និងការប្រែក្លាយទៅជាឯកសារសម្រាប់គម្រោង (Project paper) ព្រមទាំងគាំទ្របច្ចេកទេសដល់យុវជន ក្នុងការរៀបចំគម្រោងស្នើសម្រាប់ស្នើទៅដៃគូ (Project Proposal) ។
- គម្រោងចំនួន០២ ត្រូវបានទទួលការគាំទ្រពីដៃគូ និងអនុវត្តដោយសមាជិកយុវជន៖ (១.អភិវឌ្ឍភាពជាអ្នកដឹកនាំដល់ស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងសហគមន៍ព្រៃឈើ គាំទ្រដោយអង្គការវីខូស្វ ២-ការស្ទង់មតិពីការយល់ដឹងអំពីយេនឌ័រ ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនៅភ្នំពេញ គាំទ្រដោយយូអិនឌីភី)។

# វគ្គឆ្លុះបញ្ចាំង, ប្រឹក្សាយោបល់ និងហ្វឹកហ្វឺន

Self-Reflection, Consultation Support and Coaching/Mentorship

- **ក្រោយវគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នីមួយៗ៖** អ្នកចូលរួមត្រូវទទួលបានការអនុវត្តលំហាត់ឆ្លុះបញ្ចាំង ខ្លួនអំពី៖ អ្វីដែលរៀនបាន, អ្វីដែលអាចយកទៅប្រើប្រាស់សម្រាប់ខ្លួនបាន ហើយអ្វីដែលខ្លួនប្តេជ្ញាយកទៅ អនុវត្តបន្តក្រោយវគ្គ?
- **ការប្រឹក្សាយោបល់ និងហ្វឹកហ្វឺន៖** យុវជនកម្មវិធី បានទទួលការផ្តល់យោបល់ លើការរៀបចំគម្រោងស្នើ, ការរៀបចំគម្រោងថវិកា និងការដាក់ស្នើទៅដៃគូ ការរៀបចំសរសេររបាយការណ៍ ក៏ដូចជាការគាំទ្រមុនចុះទៅហាត់ការនៅកន្លែងរបស់ដៃគូ។

*ការអភិវឌ្ឍសមត្ថភាពនិងភាពជាអ្នកដឹកនាំរបស់យុវជនម្នាក់ៗ កាន់តែមានប្រសើរនៅពេលពួកគាត់ទទួលបានការគាំទ្រការប្រឹក្សា និងហ្វឹកហ្វឺនជាប្រចាំ។*

នៅក្នុងបរិបទកូវីដ-១៩ ការរៀបចំកម្មវិធីឆ្លុះបញ្ចាំង និងផ្តល់ប្រឹក្សាយោបល់ឬហ្វឹកហ្វឺន ភាគច្រើន ដំណើរការទៅតាមប្រព័ន្ធអនឡាញ (Zoom និង Telegram)។





# ការចុះហាត់ការ

Internship Opportunities from our partners





- នៅឆ្នាំ២០២០ កម្មវិធីទទួលបានឱកាសសម្រាប់ការសម្ភាសន៍ចូលហាត់ការ ពីអង្គការដៃគូកម្មវិធី រួមមាន៖ Oxfam, RECOFTC, CDRI, Coca Cola, និងUNDP។
- សមាជិកកម្មវិធី ចំនួន៣នាក់ បានចុះហាត់ការនៅក្នុងអង្គការ RECOFTC ហើយបច្ចុប្បន្នសមាជិក២នាក់ បានបន្តក្លាយជាបុគ្គលិកហាត់ការ នៅក្នុងអង្គការ RECOFTC ប្រចាំនៅកម្ពុជា ។ សមាជិកមួយចំនួនទៀត បាន និងកំពុងហាត់ការនៅក្នុងកន្លែងធ្វើការរបស់ខ្លួន។
- សមាជិកកម្មវិធីខ្លះ មិនទាន់បានហាត់ការ ដោយសារមិនត្រូវលក្ខខណ្ឌរបស់ស្ថាប័ន មួយចំនួន ហើយស្ថាប័នដៃគូមួយចំនួន មិនអាចដំណើរការកម្មវិធីហាត់ការ ដោយសារបញ្ហានៃការរីករាលដាលជំងឺកូវីដ-១៩ ។

# ការយល់ឃើញរបស់ថ្នាក់ដឹកនាំ

## អ្វីជាតម្លៃ និងលក្ខណៈពិសេសរបស់កម្មវិធី?

“

*កម្មវិធីភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ* ជាទីកន្លែងពិសោធន៍សម្រាប់យុវជន ក្នុងការអនុវត្តនូវចំណេះដឹង ការប្តេជ្ញាចិត្ត និងសក្តានុពលរបស់ខ្លួនឯង។ កម្មវិធីរៀបចំជាកញ្ចប់នៃការបណ្តុះបណ្តាល ហ្វឹកហ្វឺន ផ្តល់ឱកាសឱ្យពួកគាត់យកគំនិតឱ្យចេញជាគម្រោង និងដាក់ជាសកម្មភាព ហើយមានក្រុមសម្រាប់ជួយផ្តល់ប្រឹក្សាយោបល់ រួមទាំងការភ្ជាប់ទំនាក់ទំនងជាមួយឱកាសកន្លែងការងារ។ តាមរយៈកន្លែងពិសោធន៍របស់កម្មវិធីនេះ យុវជននឹងរកឃើញថាសមភាពយេនឌ័រគឺជាតម្លៃស្នូលរបស់ពួកគេ និងតាមរយៈភាពជាអ្នកដឹកនាំរបស់ខ្លួន។



ឯកឧត្តម ថេ ឈុនហាក់
អគ្គនាយក សមភាពយេនឌ័រនិងអភិវឌ្ឍន៍សេដ្ឋកិច្ច
ក្រសួងកិច្ចការនារី

# ការយល់ឃើញរបស់តំណាងអង្គការរីខូស្វ

## ហេតុអ្វីគាំទ្រកម្មវិធីនេះ?

“យុវជនថ្ងៃនេះ នឹងក្លាយជាអ្នកដឹកនាំនាពេលអនាគត ។ កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ នឹងបណ្តុះអ្នកដឹកនាំទាំងនេះប្រកបដោយជំនាញ និងកសាងឥរិយាបថដឹកនាំរបស់ពួកគេ ដែលឱ្យតម្លៃសមភាពយេនឌ័រជាមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចគោលដៅអង្គភាពពួកគេ ដែលនឹងធ្វើការនាពេលអនាគត ។

តាមការយល់ឃើញរបស់ខ្ញុំ កម្មវិធីនេះ ត្រូវបានរៀបចំឡើងយ៉ាងល្អ ប្រកបដោយភាពច្នៃប្រឌិត ជាមួយនឹងយុទ្ធសាស្រ្តច្បាស់លាស់ ឆ្ពោះទៅរកការសម្រេចគោលដៅ និងគោលបំណងរបស់កម្មវិធី ។ ការរួមបញ្ចូលគ្នានៃវិធីសាស្រ្តនៃការរៀនសូត្រខុសៗគ្នា ជួយឱ្យយុវជនចូលរួមយ៉ាងសកម្មក្នុងកម្មវិធី ការបណ្តុះបណ្តាល ការការចូលរួមការងារក្រុម ការចុះហាត់ការ និងចុះទស្សនកិច្ចសិក្សា។ សិក្ខាកាមបានស្វែងយល់អំពីគំនិតការអនុវត្តវិធីសាស្រ្ត ជំនាញ និងបទពិសោធន៍ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងបរិបទជាច្រើន។



លោក តុល សុខជា  តំណាងអង្គការរីខូស្វ
គ្រូបណ្តុះបណ្តាល

# ការយល់ឃើញរបស់អ្នកសម្របសម្រួល និងគ្រូបណ្តុះបណ្តាល



## លោកស្រី ចេង ជិនណេត

ប្រធាននាយកដ្ឋានសមភាពយេនឌ័រ
ក្រសួងកិច្ចការនារី

“ ខ្ញុំធ្វើការនៅក្រសួង ១២ឆ្នាំហើយ រហូតមកដល់សព្វថ្ងៃនេះ។ តាមទស្សនៈរបស់ខ្ញុំ, កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ គឺជាកម្មវិធីសំខាន់មួយសម្រាប់បណ្តុះយុវជនជំនាន់ក្រោយ ដើម្បីជាប្រយោជន៍ដល់សង្គមកម្ពុជានាពេលអនាគត។ ក្នុងនាមជាអ្នកបង្ហាត់បង្រៀន ហើយអ្វីដែលខ្ញុំចង់បាន គឺការចូលរួមចំណែកនិងចែករំលែកដល់យុវជនជំនាន់ក្រោយពីអ្វីដែលខ្ញុំបានរៀន និងចំណេះដឹងរបស់ខ្ញុំ អំពីការនិយាយជាសាធារណៈឱ្យមានប្រសិទ្ធភាព ។ យើងមិនល្អបំផុតសម្រាប់ថ្ងៃនេះទេ ប៉ុន្តែតាមរយៈសកម្មភាពតិចតួចនៅថ្ងៃនេះ គ្រាប់ពូជទាំងនេះនឹងរីកចម្រើន ហើយនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា។



## លោកស្រី ថា បូណាវី

អនុប្រធាននាយកដ្ឋានព័ត៌មាន
ក្រសួងកិច្ចការនារី

“ កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជន បានផ្តល់ជាទម្រង់យ៉ាងសំខាន់មួយដែលផ្លាស់ប្តូរនិស្សិតសាកលវិទ្យាល័យឱ្យយល់អំពីគោលគំនិតយេនឌ័រ ភាពជាអ្នកដឹកនាំ និងជំនាញទន់ ក៏ដូចជាសកម្មភាពសំខាន់ៗផ្សេងទៀត។ យោងតាមប្រធានបទបណ្តុះបណ្តាលរបស់ខ្ញុំ ដែលនិយាយអំពីជំនាញសម្របសម្រួល សមាជិកនឹងអាចយល់ពីចរិតលក្ខណៈរបស់មនុស្ស និងយល់ពីតួនាទី និងដំណើរការនៃការសម្របសម្រួលជំនាញ គឺជាជំនាញចាំបាច់មួយ ដែលមិនត្រឹមតែប្រើនៅកន្លែងធ្វើការប៉ុណ្ណោះទេ ប៉ុន្តែក៏មានគ្រប់ជ្រុងនៅក្នុងជីវិតផងដែរ។

# ការយល់ឃើញរបស់អ្នកសម្របសម្រួល និងគ្រូបណ្តុះបណ្តាល



## កញ្ញា មៀច សុទ្ធារី

អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ
ក្រសួងកិច្ចការនារី (ធ្វើការ១៩ឆ្នាំ)

“ក្នុងនាមជាគ្រូបណ្តុះបណ្តាល ដែលខ្ញុំចែករំលែកជាមួយកម្មវិធី អំពីគោលគំនិតបញ្ញាបយេនឌ័រ ខ្ញុំរំពឹងថាវាជាចំណេះដឹងមូលដ្ឋានសម្រាប់កសាងសមត្ថភាពក្នុងការផ្លាស់ប្តូរការគិតទាក់ទងនឹងយេនឌ័រជាបុគ្គល គ្រួសារ សហគមន៍ និងសង្គមជាពិសេសក្នុងភាពជាអ្នកដឹកនាំ។ យេនឌ័រគឺជាការងាររបស់យើងគ្រប់គ្នា មិនមែនតែការងាររបស់ស្ត្រីប៉ុណ្ណោះទេ។

ដោយសារយុវជនជាទំពាំងស្នងឬស្សី និងជាធនធានសម្រាប់មនុស្សជំនាន់ក្រោយ យុវជនកាន់តែយល់ដឹងអំពីយេនឌ័រកាន់តែច្រើន ការអភិវឌ្ឍប្រកបដោយបរិយាប័ននិងសមភាពយេនឌ័រ នឹងកាន់តែទទួលបានការសម្រេច ។ ដូច្នេះកម្មវិធីនេះ គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីល្អបំផុត និងចាំបាច់។



## លោក ញ៉ឹន លក្ខិណា

ប្រធានការិយាល័យ
ក្រសួងកិច្ចការនារី ធ្វើការ១២ ឆ្នាំ

“យុវជនត្រូវរៀន លើកជាគំនិត និងចែករំលែកគ្នាលើចំណុចពិសេសដែលពួកគេយល់ និងចង្អុលបង្ហាញដើម្បីឱ្យកាន់បង្កើនការវិវត្ត។ យើងអាចមើលឃើញទស្សនៈរបស់ពួកគេ ស្ថានភាពបច្ចុប្បន្នដែលពួកគេកំពុងប្រឈមមុខក្នុងការរស់នៅ ជួយពួកគេក្នុងការកសាងសង្គមមិនរើសអើងទាក់ទងនឹងយេនឌ័រ ដោយផ្តោតលើការចូលរួមយ៉ាងសកម្មសេរីភាពនៃការជ្រើសរើស ហើយអ្វីៗទាំងអស់អាចត្រូវបានគេមើលឃើញនៅក្នុងកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ។

ក្នុងនាមជាអ្នកបង្ហាត់បង្រៀន ខ្ញុំមិនសង្ឃឹមអ្វីក្រៅពីជួយយុវជនជំនាន់ក្រោយឱ្យយល់ពីមូលដ្ឋានគ្រឹះយេនឌ័រ ការចែករំលែក តម្លៃ និងសារៈសំខាន់ទាំងបុរស និងស្ត្រីនៅក្នុងសង្គម ដើម្បីឱ្យមនុស្សទាំងអស់អាចរស់នៅប្រកបដោយសុខសន្តិភាពរីករាយនឹងសុខដុមនីយកម្ម និងទទួលបានផលប្រយោជន៍រួមគ្នា។

# ការយល់ឃើញរបស់អ្នកសម្របសម្រួល និងគ្រូបណ្តុះបណ្តាល



លោក មាស ជីវុធ

ប្រធានការិយាល័យ ក្នុងនាយកដ្ឋានសមភាពយេនឌ័រ



កញ្ញា អុន ចាន់ស្រីល័ក្ខ

បុគ្គលិកហាត់ការក្រោមកម្មវិធី Youth lab

“ ខ្ញុំបានបណ្តុះបណ្តាលប្រធានបទស្តីពីគោលគំនិតយេនឌ័រ និងវដ្តនៃការរៀបចំគម្រោង។ តាមរយៈប្រធានបទទាំងនេះ ខ្ញុំរំពឹងថាប្អូនៗជានិស្សិត និងមន្ត្រីថ្មីរបស់ក្រសួងកិច្ចការនារី ទទួលបានចំណេះដឹងបន្ថែមពាក់ព័ន្ធយេនឌ័រ និងជំហាននៃដំណើរការរៀបចំគម្រោងឆ្លើយតបនឹងតម្រូវការយេនឌ័រ។

តាមរយៈ ការចូលរួមនិងការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកនេះ ខ្ញុំមានជំនឿថាពួកគាត់នឹងអាចយកចំណេះដឹង ដែលបានទៅអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន ក៏ដូចជាការចែករំលែកបន្តជាមួយគ្រួសារ និងមិត្តភ័ក្រផងដែរ។

“ ក្នុងនាមជាបុគ្គលិកហាត់ការរបស់កម្មវិធី ខ្ញុំបានឃើញពីតម្លៃនៃកម្មវិធីដែលផ្តល់ទៅសមាជិកកម្មវិធីពាក់ព័ន្ធយេនឌ័រ ភាពជាអ្នកដឹកនាំ និងជំនាញទន់ ក្នុងការយកទៅប្រើប្រាស់សម្រាប់ដំណើរទៅមុខនិងជីវិតរបស់ពួកគេ។

ការគិតគូរ និងវិនិយោគលើយុវជន គឺជាវិនិយោគឆ្លាត ដើម្បីកសាងអ្នកបន្តវេនប្រកបដោយចំណេះដឹង និងចំណេះធ្វើ ក្នុងការអភិវឌ្ឍប្រទេស។

# សមាជិកកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ

“

ខ្ញុំដាក់ពាក្យចូលរួមក្នុងកម្មវិធីនេះ ដោយហេតុផលផ្ទាល់ខ្លួន ដែលហេតុផលនីមួយៗជំរុញឱ្យខ្ញុំចូលរួមក្នុងសកម្មភាពនីមួយៗ ។ បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីនេះ ខ្ញុំទទួលបានចំណេះដឹងច្រើនលើសពីអ្វីដែលខ្ញុំរំពឹង ការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាយេនឌ័រ ក៏ដូចជាវិធីសាស្ត្រ ផ្សេងៗក្នុងការធ្វើផែនការ ការអនុវត្តការវិភាគនិងដោះស្រាយបញ្ហានានាពីទស្សនៈយេនឌ័រជាពិសេសទាក់ទងនឹងការលើកកម្ពស់យេនឌ័រនៅក្នុងប្រទេស។

ខ្ញុំសូមលើកទឹកចិត្តយុវជន និងនិស្សិតឱ្យចូលរួមកាន់តែច្រើននៅក្នុងកម្មវិធីយេនឌ័រ និងភាពជាអ្នកដឹកនាំ ព្រោះវាជាអ្វីដែលយុវជនគួរយកចិត្តទុកដាក់ក្នុងការដោះស្រាយនិងបង្កើនសមត្ថភាពផងដែរ។



កញ្ញា ស្រីម ធីតា និស្សិត
សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# តំណាងសមាជិកកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ

“ ខ្ញុំសូមកោតសរសើរចំពោះកម្មវិធី ដែលបង្កើនសមត្ថភាពនិងចំណេះដឹងរបស់ខ្ញុំលើគំនិត និងជំនាញភាពជាអ្នកដឹកនាំ។ ពេញមួយកម្មវិធីនេះ ខ្ញុំបានរៀនសូត្រយ៉ាងជ្រាលជ្រៅអំពីគោលគំនិតតស៊ូមតិ សមភាពយេនឌ័រ និងគោលគំនិតដឹកនាំ។ និយាយការពិត ខ្ញុំទទួលបានការគាំទ្រនិងការលើកទឹកចិត្តជាច្រើន ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសហគមន៍។

សមភាពយេនឌ័រ គឺជាបញ្ហាចម្បងដែលទាមទារឱ្យមានការចូលរួមពីសំណាក់យុវជន។ ដូច្នេះដើម្បីចូលរួមជាដំណោះស្រាយ ខ្ញុំធានាថាកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រជាកន្លែងល្អបំផុតសម្រាប់អ្នក។



យឿម យ៉េត និស្សិត
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ជំនាញទំនាក់ទំនងអន្តរជាតិ

# តំណាងសមាជិកកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ

“នៅពេលដែលខ្ញុំចូលរួមក្នុងកម្មវិធីនេះ ខ្ញុំរំពឹងថានឹងទទួលបានចំណេះដឹងអំពីគំនិតយេនឌ័រ និងបទពិសោធន៍ជាច្រើនទៀតអំពីសង្គមកម្ពុជា (ស្ថានភាពបច្ចុប្បន្ននិងអនាគត) ។ ឥលូវនេះវាត្រូវបានសម្រេចជាបណ្តើរៗ ហើយខ្លះទៀតកំពុងឆ្ពោះទៅមុខ។

ខ្ញុំសូមលើកទឹកចិត្តឱ្យយុវជនដាក់ពាក្យនៅក្នុងកម្មវិធី ព្រោះវាបានផ្តល់នូវចំណេះដឹង បទពិសោធន៍ និងឱកាសដែលជាធាតុសំខាន់ក្នុងការអភិវឌ្ឍខ្លួនឆ្ពោះទៅរកភាពប្រសើរបំផុត នៃជីវិតនិងក្លាយជាគំរូមួយនៅក្នុងកម្រិតដឹកនាំ។



ស៊ាប សារុធ និស្សិត
សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
ជំនាញរដ្ឋបាលសាធារណៈ

# តំណាងសមាជិកកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ

"

ចូលរួមកម្មវិធីនេះ ខ្ញុំមានការរំពឹងទុក មិនឆ្ងាយទេ តែដើម្បីស្វែងយល់ពីទំនាក់ទំនងយេនឌ័រ និងភាពជាអ្នកដឹកនាំ ក៏ដូចជាខ្ញុំចង់ទទួលបានចំណេះដឹងជំនាញទន់បន្ថែម ជាពិសេសវិធីសាស្រ្តបណ្តុះបណ្តាល។ លើសពីនេះ ខ្ញុំចង់ដឹង ចង់ឃើញ ចង់ស្វែងយល់ពីរបៀប ដើម្បីធ្វើឱ្យយុវជនចូលរួមនិងការយល់ដឹងអំពីសមភាពនិងសមធម៌យេនឌ័រ ដែលត្រូវបានសន្មតថាជាកម្លាំងចលករដ៏សំខាន់មួយ ដែលយុវជនទាំងអស់ត្រូវយកចិត្តទុកដាក់និងចាប់ផ្តើមគំនិតរបស់ពួកគេ ទៅលើវិធីពិចារណាឡើងវិញ ទាក់ទងនឹងចំណេះដឹងអំពីបញ្ហាយេនឌ័រនៅក្នុងកាលៈទេសៈណាមួយ នៃផ្លូវជីវិត។

ជាចុងក្រោយ យុវជនជាទីស្រឡាញ់ជំនាន់ក្រោយ" កុំរង់ចាំរហូតដល់ថ្ងៃស្អែក ថ្ងៃនេះដើម្បីសមភាពយេនឌ័រ"។



កញ្ញា ឆាប់ នីកា មន្រ្តីក្រសួងកិច្ចការនារី

# មេរៀនបទពិសោធន៍

- *ការអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំរបស់យុវជនម្នាក់ៗ រួមទាំងចំណេះដឹង និងឥរិយាបថឆ្លើយតបនឹងយេនឌ័រ មានការល្អលាស់តែប្រសើរនៅពេលពួកគាត់ទទួលយកពីតម្លៃនេះសម្រាប់ខ្លួនគេ ហើយទទួលបានការគាំទ្រការប្រឹក្សាយោបល់និងហ្វឹកហ្វឺនជាប្រចាំពីកម្មវិធី ដើម្បីយកទៅប្រតិបត្តិក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ។ ជាមួយគ្នានេះ សម្រាប់កម្មវិធី វដ្តកាលក្រោយ នឹងពង្រឹងនិងពង្រីកទំហំ និងការងារហ្វឹកហ្វឺនសម្រាប់សមាជិកនីមួយៗឱ្យកាន់តែជាប្រចាំបន្ថែមទៀត។*
- ក្នុងអំឡុងនៃការរីករាលដាលជំងឺកូវីដ-១៩ កម្មវិធីបានប្រែក្លាយបញ្ហាប្រឈមឱ្យទៅជាឱកាស តាមរយៈការស្វែងយល់និងចាប់យករបៀបស្របតាមបរិបទឌីជីថល ដោយរៀបចំវគ្គឆ្លុះបញ្ចាំង និងកិច្ចប្រជុំនានាតាមប្រព័ន្ធអនឡាញ (Zoom Meeting)។ ក្នុងន័យនេះ **យុវជនសមាជិកកម្មវិធី និងក្រុមការងារមានការយល់ដឹង និងសមត្ថភាពក្នុងដំណើរការតាមប្រព័ន្ធអនឡាញប្រសើរឡើងជាបន្តបន្ទាប់** ។ ជាមួយគ្នានេះ កម្មវិធីវដ្តកាលបន្ទាប់ នឹងបន្ថែមវគ្គបណ្តុះបណ្តាលខ្លី អំពីចំណេះដឹងផ្នែកប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដល់សមាជិកនៅពេលចាប់ផ្តើមកម្មវិធី ។

# សេចក្តីសន្និដ្ឋាន

- តាមរយៈកម្មវិធី សមាជិកបានបន្តការអភិវឌ្ឍសមត្ថភាពបន្ថែម ក្នុងការយកចំណេះដឹង និងជំនាញទន់ ទៅអនុវត្តន៍ជាប្រយោជន៍ក្នុងជីវិតប្រចាំថ្ងៃ  ក៏ដូចជាចែករំលែកទៅមិត្តរួមថ្នាក់ មិត្តរួមការងារ  និងសមាជិកគ្រួសារ ក្នុងស្មារតីរួមចំណែកលុបបំបាត់គម្លាតយេនឌ័រ និងប្រែក្លាយជាបុគ្គលមួយដែលមានទស្សនៈយេនឌ័រ ។
- ការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ គឺជាយុទ្ធសាស្រ្តមួយ ក្នុងការចូលរួម ដោះស្រាយបញ្ហាយេនឌ័រជាពេលបច្ចុប្បន្ន និងឈានទៅលើកកម្ពស់សមភាពយេនឌ័រ ក្នុងតួនាទីធ្វើ សេចក្តីសម្រេចនៅគ្រប់កម្រិតនាពេលខាងមុខ ។
- កម្មវិធី  ជាផ្នែកមួយចូលរួមចំណែកមួយ ក្នុងការធានាថាយុវជនទាំងស្រ្តី និងបុរស ទទួលបានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងទទួលបានការងារដែលមានប្រាក់កម្រៃខ្ពស់ ក្នុងតួនាទីជាអ្នកដឹកនាំ និងធ្វើសេចក្តីសម្រេចឈានទៅសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាល  ជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងប្រាក់ចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។

## កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជន
ដើម្បីសមភាពយេនឌ័រ

**Youth Leadership Lab**
*for Gender Equality*

យើងប្តេជ្ញា បណ្តុះយុវជន ឱ្យមានគុណភាព គុណធម៌ និងគុណតម្លៃ សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សង្គម និងមនុស្សជាតិ

www.mowa.gov.kh
mowa.gov.kh

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS


mwa@online.com.kh
www.mowa.gov.kh
fb.com/mowa.gov.kh
youtube.com/mowagovkh




*Investing in gender equality is key for sustainable development*